# តើអ្នកអាចទទួលបានវ៉ាក់សាំងបង្ការមេរោគរលាកថ្លើមប្រភេទបេ ដោយឥតគិតថ្លៃឬទេ?

រដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា បានផ្តល់វ៉ាក់សាំងដោយឥតគិតថ្លៃសម្រាប់ប្រជាជនមួយចំនួនដែលបានមកតាំងទីលំនៅនៅប្រទេសអូស្ត្រាលីក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដោយពួកគាត់ទាំងនេះមានដើមកំណើតមកពីប្រទេសដែលសម្បូរទៅដោយការឆ្លងមេរោគរលាកថ្លើមប្រភេទបេ។

ប្រទេសអាទិភាពទាំងនោះ រួមមាន ចិន ហ្វីលីពីន ម៉ាឡេស៊ី វៀតណាម អាហ្វហ្គានីស្ថង់ ថៃ កូរ៉េខាងត្បូង ភូមា ឥណ្ឌូណេស៊ី សិង្ហបុរី ហុងកុង តៃវ៉ាន់ និង*កម្ពុជា*។

ក្រុមមនុស្សផ្សេងទៀតដែលអាចទទួលវ៉ាក់សាំងដោយឥតគិតថ្លៃដែរ រួមបញ្ចូលទាំងជនភាសន៍ខ្លួន និងអ្នកមកតាំងទីលំនៅក្នុងក្របខ័ណ្ឌមនុស្សធម៌ រួមទាំងអ្នកសុំសិទ្ធិជ្រកកោន មនុស្សទាំងឡាយណាដែលមានអាយុក្រោម២០ឆ្នាំ ជនជាតិដើមភាគតិចនៅអូស្ត្រាលី (Aboriginal and Torres Strait Islanders People) ព្រមទាំងក្រុមមនុស្សដែលមានលក្ខខណ្ឌដូចជា មានផ្ទុកមេរោគអេដ៍ ឬមានមេរោគរលាកថ្លើមប្រភេទសេ (Hep C)។

«មេរោគរលាកថ្លើមប្រភេទបេ គឺជាមេរោគដែលអាចការពារបានដោយវ៉ាក់សាំង ហើយការចាក់វ៉ាក់សាំងចំនួន៣ដងប៉ុណ្ណោះ អាចការពារអ្នកពេញមួយជីវិត។» នេះបើតាមសម្តីរបស់ លោកស្រី ម៉ែក ផែរៀ (Meg Perrier) ដែលជាមន្ត្រីផ្នែកប្រមូលផ្តុំសហគមន៍ស្តីពីមេរោគរលាកថ្លើមប្រភេទបេ។ លោកស្រី បានមានប្រសាសន៍បន្តទៀតថា៖ «អ្នកដែលមិនបានចាក់វ៉ាក់សាំងគ្រប់ចំនួនទេ នឹងប្រឈមមុខក្នុងការឆ្លងមេរោគរលាកថ្លើមប្រភេទបេ ហើយមេរោគនេះ អាចបណ្តាលឲ្យកើតមហារីកថ្លើម និងស្លាប់បាន។ ដូច្នេះហើយ យើងគួរតែការពារខ្លួនឯង និងក្រុមគ្រួសារដោយគ្រាន់តែចាក់វ៉ាក់សាំងបង្ការមេរោគរលាកថ្លើមប្រភេទបេគ្រប់ចំនួនប៉ុណ្ណោះ។»

សូមអ្នកពិភាក្សាជាមួយវេជ្ជបណ្ឌិតប្រចាំគ្រួសារអ្នក ឬគិលានុបដ្ឋានិកាដើម្បីដឹងថា តើអ្នកឬគ្រួសារអ្នកត្រូវការវ៉ាក់សាំងការពាររលាកថ្លើមប្រភេទបេនេះ ឬយ៉ាងណា។